**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ក្រសួងអប់រំ យុវជន និង កីឡា
## សមិទ្ធផលឆ្នាំសិក្សា២០១១-២០១២

### គោលនយោបាយក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ

១- ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌

២- លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ

៣- អភិវឌ្ឍស្ថាប័ននិងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ

### ១- ច្បាប់ស្តីពីការអប់រំ

ច្បាប់ស្តីពីការអប់រំ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧។ លិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងច្បាប់ស្តីពីការអប់រំដែលសម្រេចបានរួមមាន៖ ព្រះរាជក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យ ព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន គោលនយោបាយសាលាកុមារមេត្រីកម្រិតមូលដ្ឋាន និងប្រកាសស្តីពីការបណ្តុះបណ្តាលថ្នាក់បណ្ឌិត។

### ២- ការងារអប់រំកុមារតូចនិងការងារអប់រំចំណេះទូទៅ

សាលាមត្តេយ្យសិក្សាទូទាំងប្រទេសមាន ៥ ៤៧០ : រដ្ឋ ២ ៨១៣ ឯកជន ៣៤៨ និងសហគមន៍ ២ ៣០៩។ កុមារមត្តេយ្យសិក្សាសរុប ៣១១ ១៥៤ នាក់ កុមារី ៤៩,៩៨ភាគរយ។

សាលាបឋមសិក្សាសរុប ៦ ៩១០ កើន ៦១។ សាលាកុមារមេត្រីកម្រិតមធ្យមនិងអភិវឌ្ឍមាន ៤ ៩៨០ ស្មើនឹង ៧២,៧១ ភាគរយ។ សាលារៀនមិនគ្រប់កម្រិតថ្នាក់មាន ៩៥២ ត្រូវជា ១៣,៧៧ ភាគរយ។ សិស្សបឋមសិក្សាមាន ២ ១៧៣ ៣៨៤ នាក់ ស្រី ៤៧,០៦ភាគរយ។

អនុវិទ្យាល័យមាន ១ ២១៤ កើន ១៨ សិស្សមធ្យមសិក្សាបឋមភូមិ មាន ៥៣៤ ៧១០នាក់ ស្រី ៤៩,២៥ភាគរយ។

វិទ្យាល័យមាន ៤៣៣ កើន ៧ សិស្សមធ្យមសិក្សាទុតិយភូមិមាន ២៨៨ ៧៨៩នាក់ ស្រី ៤៦,៦១ភាគរយ។

លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ៩៣,៥៥ភាគរយស្រី ៩៥,៥៦ ភាគរយ និងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ៨៦,៤៨ ភាគរយ ស្រី ៩១,៥៥ ភាគរយ។ សិស្សអាហារូបករណ៍មធ្យមសិក្សា បឋមភូមិ មាន ៥៤ ៧៩៨ នាក់ ស្រី ៦០ ភាគរយ និងមធ្យមសិក្សា ទុតិយភូមិមាន ៣ ៥០០ នាក់ ស្រី ៦០ ភាគរយ។

### ៣- ការងារអប់រំក្រៅប្រព័ន្ធ

អ្នកសិក្សាក្នុងកម្មវិធីអក្ខរកម្មវិជ្ជាជីវៈមាន ៣៥ ៤២៥ នាក់ ស្រី ៦១,៧១ ភាគរយ។ អ្នកសិក្សាដែលបានបញ្ចប់និងទទួលប័ណ្ណអក្ខរកម្មវិជ្ជាជីវៈសរុប ២៦ ៨៩០ នាក់ ស្រី ៦៦,៤៩ ភាគរយ។ មជ្ឈមណ្ឌលសិក្សាសហគមន៍ ៣២១ កន្លែង អ្នកសិក្សា ១០ ៥០៧ នាក់ ស្រី ៦០,០៥ ភាគរយ។ អ្នកដែលបានបញ្ចប់ការសិក្សាមាន ៧ ៥៣៧ នាក់ ស្រី ៦៤,៧៦ ភាគរយ។

### ៤- ការងារឧត្តមសិក្សា

គ្រឹះស្ថានឧត្តមសិក្សាមាន ១០១កន្លែង រដ្ឋ ៣៩ និងឯកជន ៦២ មាន ទីតាំងនៅ ១៩ ខេត្ត និងរាជធានីភ្នំពេញ។ គ្រឹះស្ថានឧត្តមសិក្សាដែល ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡាមាន ៦១ (រដ្ឋ ៩ និង ឯកជន ៥២)។ និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្ររង មាន ២៣ ៦៧៨ នាក់ ស្រី ៣៣,៦០ ភាគរយ ថ្នាក់បរិញ្ញាបត្រមាន ២១៦ ០៥៣ នាក់ ស្រី ៣៩,៩១ ភាគរយ។ និស្សិតបញ្ចប់ការសិក្សាមាន ៣៤ ៩៧៨ នាក់ ស្រី ៤១,៣ ភាគរយ។ និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ១៤ ៩៩៧ នាក់ ស្រី ១៩,២៣ ភាគរយ។ បេក្ខជន ថ្នាក់បណ្ឌិតសរុប ១ ០៦៣ នាក់ ស្រី ៥,៣៦ ភាគរយ។

### ៥- ការងារយុវជន

ក្រុមប្រឹក្សាយុវជនមាន ៤១៦ ក្រុម ដែលមានសមាជិក ២៧៤ ៩៧៤ នាក់ ស្រី ៤៩ ភាគរយ និងក្រុមប្រឹក្សាកុមារ ៦ ៩៧៨ ដែលមានសមាជិក ១ ៤៦១ ០២៧ នាក់ ស្រី ៤៩ ភាគរយ។ សមាជិកក្រុមប្រឹក្សាយុវជននិងកុមារ ៤៨០នាក់ ស្រី ៥០ ភាគរយ មានស្នាដៃក្នុងសកម្មភាព "កូនល្អ សិស្សល្អ មិត្តល្អ"។

### ៦- ការងារកីឡា

កីឡាករ ២០០ នាក់ ស្រី ២៣ ភាគរយ បានចូលរួមប្រកួតកីឡាអន្តរជាតិ ៧ លើក ទទួលបាន មេដាយមាស ២ គ្រឿង ប្រាក់ ២ គ្រឿង និងសំរិទ្ធ ១៧ គ្រឿង ។

### ៧- ការងារបណ្តុះបណ្តាលនិងវិក្រឹតការ

គ្រឹះស្ថានបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបង្រៀនគ្រប់កម្រិតសិក្សាមាន ២៧ ក្នុងនោះសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម ១ សាលាគរុកោសល្យនិងគរុកោសល្យនិងវិក្រឹតការ រាជធានី ខេត្តចំនួន ១៨ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ៦ វិទ្យាស្ថានជាតិអប់រំ ១ និងវិទ្យាស្ថានជាតិអប់រំ កាយ និងកីឡា ១។ បានប្រឡងជ្រើសរើស គ្រូបង្រៀនគ្រប់ភូមិសិក្សា ៤ ៧៩៥ នាក់ ស្រី ៥៨,៤៧ ភាគរយ និងបន្តបណ្តុះបណ្តាលគរុសិស្សឆ្នាំទី២ ចំនួន ៣ ៦០៧ នាក់ ស្រី ៦៣,១២ ភាគរយ។ គ្រូបង្រៀនដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលគ្រប់ភូមិសិក្សាមាន ៤ ៦០៤ នាក់ ស្រី ៥១,៦៥ ភាគរយ ។

### ៨- ការងារព័ត៌មាននិងកិច្ចការអាស៊ាន

ក្រសួងបានផ្សព្វផ្សាយសកម្មភាពអប់រំ សេចក្តីប្រកាសព័ត៌មាន សេចក្តីជូនដំណឹង អត្ថបទរូបភាព ព័ត៌មានអប់រំ យុវជន និងកីឡា តាមរយៈវិទ្យុ ទូរទស្សន៍ ទំព័រសារព័ត៌មានជាតិ និងអន្តរជាតិ និងគេហទំព័រ ជាពិសេសយុទ្ធនាការផ្សព្វផ្សាយស្តីពីការចុះឈ្មោះចូលរៀនកុមារអាយុ ៦ ឆ្នាំ។ មានកិច្ចសហប្រតិបត្តិការជាមួយប្រទេសជាដៃគូក្នុងតំបន់ និងពិភពលោក។

### ៩- ការងារសំណង់សិក្សា

ក្រសួងបានសាងសង់អគារសិក្សា នៅសាលាបឋមសិក្សាមិនគ្រប់កម្រិតនិងសាលាមានសិស្សច្រើន ៤២៣ ខ្នង សាលាមត្តេយ្យធនធាន ២៥ ខ្នង និងសាលាមត្តេយ្យសិក្សា ១ ខ្នង ៣ ជាន់។ សាងសង់ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ៦០ ខ្នង។ មកដល់បច្ចុប្បន្ននេះ អគារសិក្សាជាអំណោយដ៏ថ្លៃថ្លារបស់ **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **លោកជំទាវ កិត្តិព្រឹទ្ធបណ្ឌិត** មាន ៣ ៥១៨ ខ្នង ស្មើនឹង ១៨ ២៥៦ បន្ទប់ (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២)។

### ១០- ការងារបោះពុម្ពនិងចែកផ្សាយ

ក្រសួងបានអភិវឌ្ឍសៀវភៅសិស្សថ្នាក់ទី៦ ចំនួន ៩មុខវិជ្ជា។ បាន អភិវឌ្ឍសៀវភៅគ្រូថ្នាក់ទី១១ និងទី១២ ចំនួន ១២មុខវិជ្ជា។ បាន អភិវឌ្ឍសៀវភៅហ្វឹកហាត់ថ្នាក់ទី១ ទី២ និងទី៣ ចំនួន ១២មុខវិជ្ជា និងសៀវភៅអំណានបន្ថែមចំនួន ១៥ ចំណងជើង។ ក្រសួងបានបោះពុម្ពសៀវភៅ ៣ ៣៨០ ៣៩៥ ច្បាប់ និងបានដឹកជញ្ជូនទៅសាលារៀន។

# ១១- ការងារផែនការនិងស្ថិតិអប់រំ

## វឌ្ឍនភាពនៃការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាឆ្នាំ២០១៥

| ចំណុចដៅ CMDG | ជាក់ស្តែង ២០១២ | | ចំណុចដៅ ២០១៥ | | |
|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | |
| អត្រាពិតនៃការសិក្សានៅបឋមសិក្សា | ៩៧% | ៩៧% | ១០០% | ១០០% | ↑ |
| អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា | ៨៧,៣៥% | ៨៧,៨២% | ១០០% | ១០០% | → |
| សន្ទស្សន៍យុគភាពយេនឌ័រ | ១ | | ចន្លោះពី ០,៩៧-១,០៣ | | ↑ |
| អត្រាត្រួតថ្នាក់នៅបឋមសិក្សា | ៥,៣% | ៤,៥% | ≤១០,០% | ≤១០,០% | ↑ |
| អត្រាបោះបង់នៅបឋមសិក្សា | ៣,៧% | ៤,៧% | ≤៥,០% | ≤៥,០% | ↑ |

↑ អាចសម្រេចបាន → ខិតខំថែមទៀត

**កម្ពុជានឹងសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី ២ "សកលកម្មអប់រំបឋមសិក្សា" នៅឆ្នាំ ២០១៥**




## ហិរញ្ញប្បទានសហប្រតិបត្តិការ

| ដៃគូអភិវឌ្ឍធំៗទាំង១០ (ពាន់ដុល្លា) | ចំណាយធនធានផ្ទាល់ខ្លួន២០១២ | ផែនការឆ្នាំ ២០១៣ | ផែនការឆ្នាំ ២០១៤ | ផែនការឆ្នាំ ២០១៥ |
|---|---|---|---|---|
| IBRD/ធនាគារពិភពលោក | ២២៥៧៤ | ៦០០០ | ៤៦០០ | ០ |
| ធនាគារអភិវឌ្ឍអាស៊ី | ១២៥៥០ | ១១៦០០ | ១៣៧០០ | ០ |
| សាធារណៈរដ្ឋកូរ៉េ | ៧០៥២ | ៩៤២៩ | ៤៦៥៨ | ០ |
| ប្រទេសជប៉ុន | ៥៤២៥ | ៣៤៦១ | ៣០៣២ | ២៩៤ |
| ប្រទេសស៊ុយអែត | ៣៨៣០ | ១០៤៣៧ | ៧៣២៤ | ៧៣២៤ |
| ប្រទេសអាមេរិក | ៣៤៤២ | ០ | ០ | ០ |
| ប្រទេសនូវែលសឺឡង | ២០៤០ | ៤០៤០ | ០ | ០ |
| អង្គការយូនីសែហ្វ | ២០១៤ | ៤០០០ | ៤០០០ | ០ |
| អង្គការស្បៀងអាហារពិភពលោក | ១៨៤៨ | ១៨៤៨ | ១៨៤៨ | ១៨៤៨ |
| សហគមន៍អឺរ៉ុប | ១២៣៦ | ១៥៧៧៦ | ៤០០ | ៣៨ |

| សូចនាករសំខាន់ចាំបាច់សម្រាប់ សម្រេចគោលនយោបាយ | ជាក់ស្តែង ឆ្នាំ 2013 | ចំណុចដៅ ឆ្នាំ 2013 | |
|---|---|---|---|
| **គោលនយោបាយទី១៖**ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ | | | |
| - ភាគរយកុមារអាយុ៥ឆ្នាំក្នុងការអប់រំកុមារតូចតាមគ្រប់រូបភាព | 56.5% | 60% | ↑ |
| - ចំនួនស្រុកដែលបានសម្រេចអត្រាបញ្ចប់បឋមសិក្សាយ៉ាងតិច ៨០ភាគរយ | 119 | 121 | ↑ |
| **គោលនយោបាយទី ២ ៖**លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ | | | |
| - ចំនួនសាលារៀនបឋមសិក្សាគ្រប់កម្រិតដែលមានអត្រាត្រួតថ្នាក់តិចជាង ១០ភាគរយ | 4967 លើ 5462 | 4464 លើ 5462 | ↑ |
| - ស្តង់ដារជាតិវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស | | | |
| ថ្នាក់ទី៣ | កំពុងអនុវត្ត | បញ្ចប់ | → |
| ថ្នាក់ទី៦ | មិនទាន់អនុវត្ត | បញ្ចប់ | ↓ |
| ថ្នាក់ទី៨ | មិនទាន់អនុវត្ត | បញ្ចប់ | ↓ |
| **គោលនយោបាយទី ៣ ៖**អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ | | | |
| - ការដកសាច់ប្រាក់ទាន់ពេលនៃថវិកាកម្មវិធី | 87.59% | 95% | → |
| - ផែនការប្រតិបត្តិប្រចាំឆ្នាំថ្នាក់ក្រោមជាតិត្រូវបានរៀបចំ | 24 | 24 | ↑ |

↑ សម្រេចតាមចំណុចដៅ → អាចទទួលយកបាន ↓ មិនសម្រេចតាមចំណុចដៅ

| សូចនាករ ៖ សមធម៌នៃការចូលរៀន | ជាក់ស្តែង 2012-2013 | | ចំណុចដៅ 2012-2013 | | |
|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | |
| ភាគរយកុមារអាយុ៥ ឆ្នាំក្នុងកម្មវិធីអប់រំកុមារតូចតាមគ្រប់រូបភាព | 56.5% | 49.5% | 55.0% | 55.0% | ↑ |
| អត្រាពិតចូលរៀនថ្មី | 94.3% | 94.2% | 98.0% | 98.0% | → |
| អត្រាពិតនៃការសិក្សានៅបឋមសិក្សា | 97.0% | 97.0% | 97.0% | 97.0% | ↑ |
| អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | 53.6% | 54.2% | | | |
| អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | 27.4% | 26.4% | | | |
| ចំនួននិស្សិតនៅគ្រឹះស្ថានឧត្តមសិក្សាទាំងសាធារណៈ និងឯកជន | 216,053 | 86,235 | 199,006 | 89,086 | ↑ |
| ចំនួនអក្ខរជនសរុបអាយុ ១៥-២៤ឆ្នាំ | 91.5% | | 91.0% | | ↑ |

↑ សម្រេចតាមចំណុចដៅ → អាចទទួលយកបាន ↓ មិនសម្រេចតាមចំណុចដៅ

| សូចនាករ ៖ គុណភាពនិងប្រសិទ្ធភាពនៃការអប់រំ | ជាក់ស្តែង 2012-2013 | | ចំណុចដៅ 2012-2013 | | |
|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | |
| ផលធៀប សិស្ស-ថ្នាក់ នៅបឋមសិក្សា | 36.9 | | 45.5 | | → |
| ផលធៀប គ្រូ-ថ្នាក់ នៅបឋមសិក្សា | 0.76 | | 0.95 | | → |
| អត្រាត្រួតថ្នាក់(2011- 2012) | | | | | |
| បឋមសិក្សា | 5.3% | 4.5% | 6.0% | 6.0% | ↑ |
| មធ្យមសិក្សាបឋមភូមិ | 1.5% | 1.0% | 1.4% | 1.2% | → |
| មធ្យមសិក្សាទុតិយភូមិ | 1.7% | 1.1% | 2.2% | 1.2% | ↑ |
| អត្រាបោះបង់ការសិក្សា (2011- 2012) | | | | | |
| បឋមសិក្សា | 3.7% | 4.7% | 6.0% | 6.0% | → |
| មធ្យមសិក្សាបឋមភូមិ | 20.0% | 18.7% | 13.0% | 15.0% | ↓ |
| មធ្យមសិក្សាទុតិយភូមិ | 10.1% | 9.8% | 9.0% | 8.0% | → |
| អត្រាបញ្ចប់ការសិក្សា | | | | | |
| បឋមសិក្សា | 87.35% | 87.82% | 95.0% | 95.0% | → |
| មធ្យមសិក្សាបឋមភូមិ | 40.62% | 40.35% | 52.0% | 51.0% | → |
| មធ្យមសិក្សាទុតិយភូមិ | 27.0% | 25.25% | 30.0% | 28.0% | ↑ |
| ចំនួនសិស្សចូលរៀនឡើងវិញថ្នាក់ទី៣ដល់ទី៦ | 21,189 | | 22,000 | | ↑ |
| ចំនួនសាលារៀនបឋមសិក្សាមិនគ្រប់កម្រិត | 952 | | 1,011 | | ↑ |
| ផលធៀប សៀវភៅ-សិស្សនៅថ្នាក់ទី ១-៣ (១ សម្រាប់ មាន៣ក្បាល) | 2.99 | | 3.0 | | ↑ |
| ផលធៀប សៀវភៅ-សិស្សនៅថ្នាក់ទី ៤ -៦ ( ១សម្រាប់ មាន៤ក្បាល) | 3.85 | | 4.0 | | ↑ |
| ស្តង់ដារវាយតម្លៃលទ្ធផលសិក្សារបស់សិស្សលើមុខវិជ្ជាភាសាខ្មែរ | | | | | |
| ថ្នាក់ទី ៣ | កំពុងអនុវត្ត | | បញ្ចប់ | | → |
| ថ្នាក់ទី ៦ | មិនទាន់អនុវត្ត | | បញ្ចប់ | | ↓ |
| ស្តង់ដារវាយតម្លៃលទ្ធផលសិក្សារបស់សិស្សលើមុខវិជ្ជាគណិតវិទ្យា | | | | | |
| ថ្នាក់ទី ៣ | កំពុងអនុវត្ត | | បញ្ចប់ | | → |
| ថ្នាក់ទី ៦ | មិនទាន់អនុវត្ត | | បញ្ចប់ | | ↓ |
| ភាគរយគ្រឹះស្ថានឧត្តមសិក្សាសាធារណៈនិងឯកជនគោរពតាមលក្ខខណ្ឌនៃការបង្កើត | 70% | | 85% | | → |

↑ សម្រេចតាមចំណុចដៅ → អាចទទួលយកបាន ↓ មិនសម្រេចតាមចំណុចដៅ

| សូចនាករ ៖ អភិវឌ្ឍស្ថាប័ន និងសមត្ថភាព | ជាក់ស្តែង 2012 | ចំណុចដៅ 2012 | |
|---|---|---|---|
| ថវិកាចរន្តសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា (រដ្ឋ និងថវិកាផ្សេងៗទៀត) ធៀបនិងថវិកាជាតិ | 15.92% | 20.0% | → |
| ភាគរយចំណាយថវិកាកម្មវិធីជាក់ស្តែង ធៀបនឹងថវិកាកម្មវិធីសរុប | 86.71% | 95.0% | → |
| ភាគរយអង្គភាពអនុវត្តថវិកាដែលត្រូវធ្វើសវនកម្មផ្ទៃក្នុងក្នុង១ឆ្នាំ | 54% | 77.2% | → |
| ភាគរយសាលារៀនគ្រឹះស្ថានសិក្សាត្រូវធ្វើសវនកម្មផ្ទៃក្នុងក្នុង១ឆ្នាំ | 7.3% | 7.75% | ↑ |
| ជំនួយការបច្ចេកទេស(នាក់-ខែ) ថ្នាក់ជាតិនិងអន្តរជាតិ | 212 | 400 | ↑ |
| ភាគរយមន្ត្រីអប់រំជាស្ត្រី | 41% | | ↑ |
| - បុគ្គលិកបង្រៀន | 44% | | ↑ |
| - មន្ត្រីគ្រប់គ្រងថ្នាក់មធ្យម(ប្រធានអនុប្រធាននាយកដ្ឋាននិងមន្ទីរអយករាជធានីខេត្ត) | 10% | | ↓ |
| - ថ្នាក់ដឹកនាំ (ចាប់ពីអគ្គនាយករងឡើងទៅ) | 7% | | ↓ |

↑ សម្រេចតាមចំណុចដៅ → អាចទទួលយកបាន ↓ មិនសម្រេចតាមចំណុចដៅ

*ផលិតនៅខែមីនា ឆ្នាំ២០១៣*